# ប្រសិនបើពួកគេនៅជាមួយយើង

## ដោយ  ចាន់ ដានី

*ប្រសិនបើពួកគេនៅជាមួយយើង* បន្តខ្សែស្រឡាយនៃប្រវត្តិសាស្ត្រសំខាន់និងជាប់ទាក់ទង
គ្នាពីរគឺ មួយរបស់វិស័យគំនូរនៅកម្ពុជា និងមួយទៀតរបស់រឿងរាមកេរ្តិ៍ ដែលជាការបកស្រាយ
កម្លាយបែបពុទ្ធសាសនាដែលមានការស្ញប់ស្ញែងចេញពីកំណាព្យវីរកថាឥណ្ឌាបែបហិណ្ឌូបុរាណ
រឿងរាមាយណា។ ក្នុងរឿងនោះ បញ្ហាការទុកចិត្ត ភក្តីភាព ក្តីស្រឡាញ់ និងការសងសឹង ត្រូវបាន
សម្តែងចេញមកតាមរយៈការប្រឈមដាក់គ្នាយ៉ាងសោកសង្រេងរវាងតួអង្គស្តេច និងទេវៈកថា។

រឿងរាមកេរ្តិ៍ នៅតែជាប្រភពគំនិតបំផុសចម្បង និងមធ្យោបាយផ្ទេរន័យក្នុងទសន្សនីយភាព
បែបផ្សេងៗគ្នានៅកម្ពុជា រីឯទម្រង់គំនូររបស់រឿងនេះវិញត្រូវបានថយចុះ។ តួនាទីសាសនា និងសង្គម
របស់វិស័យគំនូរ ធ្លាប់តែឃើញមានក្នុងបរិបទទីអារាមពុទ្ធសាសនា និងព្រះរាជវាំងតាមរយៈការបង្ហាត់
ជំនាញ។ ដោយសារប្រព័ន្ធនេះចេះតែសាបរលាបទៅ វិចិត្រករគោចរដែលគួរឱ្យគេជាច្រើនរូប បាន
កាត់ផ្តាច់ពីរឿងរ៉ាវដែលពួកគេពណ៌នា ហើយចំណេះដឹងដ៏ផូរផង់នៃការគូរឡើងវិញឈុតស្លៀកពាក់
និងរចនាបថបែបបុរាណកំពុងតែត្រូវបាត់បង់ដោយការប្រើស្តិនស៊ីល និង ឧបករណ៍កម្រិតទាប។

ចាន់ ដានី នៅតែជាសិល្បករដែលកម្ររកបាន ដោយប្រើចំណេះដឹងបែបបុរាណ និង
ព្យាយាមរក្សានូវចំណងទាក់ទងនាសព្វថ្ងៃ។ ដានី ត្រូវបានបណ្តុះបណ្តាលនៅសាលាសិល្បៈរ៉េយំ។
គាត់បានចំណាយពេលរាប់ឆ្នាំ ជាមួយលោកគ្រូ ឌួង សារី និង គុណ សុវណ្ណារិទ្ធ ដើម្បីសិក្សាពីគំរូ
ដែលនៅរក្សាធាតុដើមបំផុតនៃគំនូរលើជញ្ជាំងរបស់រឿងរាមកេរ្តិ៍ ពេញផ្ទៃប្រទេសកម្ពុជា រួមទាំងគំនូរ
នៅព្រះវិហារព្រះកែវមរកត នៅព្រះបរមរាជវាំងនៅភ្នំពេញផង។ គំនូរលើជញ្ជាំងនេះត្រូវបានគូរជា
រចនាបថរបស់អភិជនបែបសាំញ៉ាំក្នុងឆ្នាំ ១៩០៣ ក្រោមការណែនាំរបស់លោកគ្រូជំនាញអ្នកឧកញ៉ា
ទេព និមិត្តម៉ក់ ហើយជះឥទ្ធិពលយ៉ាងខ្លាំងដល់លោកគ្រូជំនាញក្រោយៗមកទៀត។ ជេត ចន គឺជា
លោកគ្រូជំនាញខាងគំនូរនេះឯង ដោយចំណេះដឹងពីគំនូររឿងរាមកេរ្តិ៍របស់លោកគ្រូត្រូវបានសហ-
ស្ថាបនិកនិងអ្នកស្រាវជ្រាវរបស់រ៉េយំគឺ អាំងគ្រីដ មួអាន់ និង លី តារាវុធ ចងក្រងជាឯកសារយ៉ាង
ម៉ត់ចត់។ *ប្រសិនបើពួកគេនៅជាមួយយើង* យកតាមវចនានុក្រមតួអង្គដោយលោក ជេត ចន ដោយ
ដាក់តួអង្គទាំងនោះតាមតួនាទី និងបរិបទថ្មី នៃតំបន់ទីក្រុងនិងជាយក្រុងថ្មីៗរបស់ភ្នំពេញសព្វថ្ងៃ។

ចាន់ ដានី កើតនៅឆ្នាំ១៩៨៤ យល់ថាខ្លួនឯងជាផ្នែកមួយនៃពលរដ្ឋកម្ពុជាសម័យថ្មីដែល
រសនិយមរបស់ខ្លួនត្រូវបានកែប្រែស្ទើរតែមិនដឹងខ្លួនដោយសេដ្ឋកិច្ចសកល។ គាត់ក្តោបយកទស្សនៈ
ថ្មីនេះ ដោយអមនឹងការបញ្ចូលដោយចេតនានូវទស្សនៈបុរាណ។ ពេលគាត់គូរតួអង្គពីបុរាណៗ
គាត់អុជធូបនៅក្បែរកន្លែងធ្វើការរបស់គាត់ ថែមទាំងស្តាប់បទកូរ៉េពេញនិយមផង។ ទន្ទឹមនឹងការ
ឱ្យតម្លៃដល់ក្បួន និងច្បាប់បុរាណដោយប្រយោល បណ្តុំពណ៌ឆើតរបស់គាត់មានលក្ខណៈដូចនឹង
រូបលម្អពិធីបុណ្យទាននាពេលសព្វថ្ងៃ។

វិចិត្រករអនាមិកសម័យមុនភាគច្រើនដែលមានជំនាញដូចគាត់ ដូចជាវិចិត្រករតាមវត្តដែល
បញ្ចូលសិល្បៈបារាំងក្នុងសម័យអាណានិគមនៅវត្តបាគង នៅសៀមរាប និងអគារទំនើបនៅវត្តរការ
នៅក្រចេះ។ ដូចពួកគាត់ ដានី ប្រើវិធីសម្របលក្ខណៈក្នុងស្រុក ដើម្បីរក្សាអតីតកាលដែលទាក់ទិន
សម្រាប់ទស្សនិកជន។ ផ្ទាំងគំនូរនីមួយៗបង្ហាញយ៉ាងប្រស៊ប់នូវការផ្លាស់ប្តូរនូវឥរិយាបថ សេដ្ឋកិច្ច
និងលក្ខណៈវប្បធម៌។ សិល្បករយើងនិយាយថា «តួអង្គរឿងរាមកេរ្តិ៍ ចេះឫទ្ធិសិល្ប៍ក្នុងរឿងពីមុន
តែពេលដាក់ចូលដល់សម័យបច្ចុប្បន្ន ពួកគេបាត់បង់រិទ្ធិអំណាចអស់។ ឥឡូវពួកគេត្រូវរកប្រាក់
ព្រោះ សព្វថ្ងៃយើងមិនអាចជឿលើឫទ្ធិសិល្ប៍ទេ។» ដានី ស្រមៃថាតួអង្គទាំងនោះត្រូវប្រឈមនឹង
ជីវិតដូចជាជនសាមញ្ញថ្នាក់កណ្តាលដែលចេះតែកើនឡើង ក្នុងប្រទេសកម្ពុជាសព្វថ្ងៃ។

*មច្ឆានុព្វ អ្នកបម្រើអាហារ* និយាយពីស្វាពាក់កណ្តាល ត្រីពាក់កណ្តាល ដែលមានការងារ
ក្រៅម៉ោងជាអ្នកបម្រើភីហ្សា ដល់គូស្នេហ៍ក្មេងៗដែលរវល់នឹងទូរស័ព្ទជាជាងទាក់ទងគ្នា។ *ពិភេក
គ្រូបង្រៀនភាសាអង់គ្លេស* ដែលធ្លាប់ជាហោរាដែលគេឯងគោរព និងជាស្តេចនគរលង្កា ឥឡូវកំពុង

# If They Were With Us Today

## Chan Dany

*If They Were With Us Today* continues the lineage of two important and interconnected histories—that of Cambodian painting, and of the Reamker—a revered Buddhist re-interpretation of the ancient Indian Hindu epic poem Ramayana in which issues of trust, loyalty, love, and revenge are played out in dramatic encounters between royal and mythical characters.

While the Reamker remains a primary inspiration and medium of moral transmission in various genres of performance in Cambodia, its painted form has diminished. The religious and social role of painting was once found within the context of Buddhist monasteries and royal courts through apprenticeship. As that system continues to fade, many itinerant painters for-hire are disconnected from the stories they depict, and refined knowledge of traditional rendering, costuming, and style are becoming lost to the use of stencils and low-grade materials.

Chan Dany remains one of very few artists employing traditional knowledge, attempting to maintain its relevance today. Trained at Reyum Art School, Chan spent years with teachers Duong Saree and Kun Sovanarith studying the most intact examples of Reamker murals throughout Cambodia including that of the Silver Pagoda at the Royal Palace in Phnom Penh. Painted in the intricate aristocratic style in 1903 under the guidance of master Neak Okhna Tep Nimit Mak, this mural was highly influential to subsequent masters. Chet Chan was one such master, whose knowledge of Reamker painting was thoroughly documented by Reyum's co-founders and scholars Ingrid Muan and Ly Daravuth. *If They Were With Us Today* follows Chet Chan's dictionary of characters, placing them in new roles and contexts of today's urban and newly suburban Phnom Penh.

Born in 1984, Chan Dany sees himself as part of a new age of Cambodians, whose tastes are altered almost unconsciously by a global economy. He embraces the new alongside his deliberate inclusion of the traditional; when he paints ancient characters, Chan offers incense at a shrine near his workstation while listening to K-pop.  While honoring traditional ritual and rules on perspective, his bright color combinations are more typical of festive decorations today.

Like his mostly anonymous predecessors, such as the temple painters who incorporated Frenchmen during colonial times Wat Bakong in Siem Reap or modern buildings at Wat Roka in Kratie, Chan uses localization tactics to keep the past relevant for audiences. Each painting subtly indicates changes in attitudes, economy and cultural practices. Says the artist, "The Reamker characters were capable of magic in the old stories, but placed in their contemporary setting they have lost their powers. They have to earn money now; today we cannot believe in magic." Chan imagines the characters facing life as the rising set of middle class commoners in Cambodia today.

*Menchanub, The Waiter* depicts a young half-fish half-monkey with a part-time job serving pizza to young couples interacting with their phones more than each other. *Pipeat, The English Teacher*, once a respected fortune-teller and King of Langka, is now volunteering to teach the "language of the future" required to gain employment in a tourist driven economy. *Asophat, The Football Fan* closely watches English Premier League on the newest flat screen television. Even Hanuman the great warrior becomes *Hanuman, The Balloon Seller*; a young boy waves him a US dollar rather than a Cambodian riel.

In the gallery, Chan Dany's collection of monoscenes and accompanying short narratives can be read from a field of individual desk-like podiums. Inter-related, these characters are autonomous in presence and in spirit. The 'sala' encourages a remembrance that they are still here to teach us something.

+855 (0)17774864
www.sasabassac.com
#18 2nd Floor, Sothearos Boulevard
PO Box 2181 Phnom Penh 3, Cambodia
ស-សបាសាក់ SA SA BASSAC

# ប្រសិនបើពួកគេនៅជាមួយយើង
## ដោយ  ចាន់ ដានី

# If They Were With Us Today
## Chan Dany

3 May - 3 June, 2012



*Sovann Macha, Health Club Member*, 2012
20 x 35 cm | guache and tempera on acid free paper

ស្មុំគ្រចិត្តបង្រៀន «ភាសាអនាគត» ដែលចាំបាច់ដើម្បីបានការងារធ្វើក្នុងសេដ្ឋកិច្ចដែលពឹងលើទេសចរ។ *អសុរផាត់អ្នកគាំទ្របាល់ទាត់* តាមដានការប្រកួត អ៊ីងគ្លីសព្រីមារលីក យ៉ាងកៀកកិតតាមទូរទស្សន៍អេក្រង់សំប៉ែតថ្មី។ សូម្បីតែហនុមានដែលជាអ្នកចម្បាំងដ៏ពូកែក្លាយជា *ហនុមាន អ្នកលក់ប៉េងប៉ោះ* មានក្មេងតូចម្នាក់ហុចប្រាក់ដុល្លារសហរដ្ឋអាមេរិកឱ្យគាត់ ជាជាងប្រាក់រៀលរបស់ខ្មែរ។

ក្នុងវិចិត្រសាល រូបភាពនីមួយៗ និងអត្ថបទនិទានអមខ្លីៗរបស់ ចាន់ ដានី អាចអានបានជាបែបវាលវេទិការាងតុធ្វើការដោយឡែកៗ។ តួអង្គទាំងនេះមានការពាក់ព័ន្ធគ្នា តែក៏មានស្វ័យភាពតាមវត្តមាន និងស្មារតីរបស់ខ្លួនដែរ។ «សាលា» ជម្រុញឱ្យស្មារតីចងចាំដែលថាពួកគេនៅរស់ ដើម្បីបង្រៀនយើងអ្វីម្យ៉ាង។

**អំពីសិល្បករ**

វិជ្ជាដ៏ស្មុគស្មាញរបស់ ចាន់ ដានី (កើត នៅព្រៃវែង ឆ្នាំ១៩៨៤) រួមបញ្ចូលការកោតសសើរ និងភាពស្ទាត់របស់គាត់ខាងទម្រង់ បច្ចេកទេស និងរឿងបុរាណ ជាវិធីមួយដើម្បីអភិរក្ស និងរក្សាចំណងទាក់ទងនាសព្វថ្ងៃ។ ពិព័រណ៍សម្រាំងៗរួមមាន *ស្រកាអង្គរ* នៅសណ្ឋាគារ ដឺឡាប៉េ ២០១១, *ក្ដីសង្ឃឹមថ្មីរបស់អាស៊ី* គម្រោង ប៉ាឡេ នៅ វាណា ២០០៩, *ពីមុនមកដល់ឥឡូវ* នៅវិចិត្រសាល ចានសឺរីឡេន ហុងកុង ២០០៩, *យុទ្ធសាស្ត្រពីខាងក្នុង* នៅមជ្ឈមណ្ឌលសិល្បៈសហសម័យ នៅ សៀងហៃ ២០០៨ និង *បណ្ដោះអាសន្ន* នៅ រីយំ ភ្នំពេញ ២០០៧។

**About the Artist**

Chan Dany's (b. Prey Veng, 1984) intricate practice combines his appreciation and fluency of traditional forms, techniques, and stories as a way to preserve and maintain their relevance today. Select exhibitions include *The Scale of Angkor*, Hotel de La Paix Arts Lounge, 2011; *New Asian Promises*, Palais Project, Vienna 2009; *Forever Until Now*, 10 Chancery Lane Gallery, Hong Kong, 2009;  *Strategies from Within*, Ke Centre of Contemporary Art, Shanghai 2008, and *In Transition*, Reyum, Phnom Penh, 2007.